# សិទ្ធិមូលដ្ឋានរបស់ម្ចាស់ភាគហ៊ុនតាមច្បាប់កម្ពុជា

ដោយមេធាវី គឹម សាន*

## ១. សេចក្តីផ្តើម

ម្ចាស់ភាគហ៊ុនមានសិទ្ធិជាច្រើន ក្នុងនាមជាអ្នកវិនិយោគនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មមួយ។ ទោះបីជាយ៉ាងណាក្តី គេអាចចាត់ថ្នាក់សិទ្ធិតាមផ្លូវច្បាប់របស់ម្ចាស់ហ៊ុនណាម្នាក់ជាបួនក្រុមដែលរួមមាន៖ *សិទ្ធិគ្រប់គ្រង សិទ្ធិខាងសេដ្ឋកិច្ច សិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិធ្វើបណ្តឹង*។[1] មាត្រា១២៤ នៃច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ (តទៅនេះ នៅក្នុងអត្ថបទនេះកាលណាប្រើពាក្យមាត្រាគឺសំដៅទៅលើ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ លើកលែងតែមានការកំណត់ពិសេសផ្សេងពីនេះ) ចែងពីសិទ្ធិរបស់ម្ចាស់ភាគហ៊ុនក្នុងការដកហូតអភិបាលចេញពីមុខតំណែង (*សិទ្ធិគ្រប់គ្រង*)[2]។ មាត្រា១៥៤ ចែងពីភាគហ៊ុនដែលជាកម្មវត្ថុ នៃការផ្ទេរបាន ហើយ មាត្រា១៥៧ ចែងពី សិទ្ធិនៃការចែកភាគលាភរបស់ម្ចាស់ភាគហ៊ុន។[3] (*សិទ្ធិខាងសេដ្ឋកិច្ច*)។ មាត្រា២២៥ ចែងពីសិទ្ធិទទួលបានព័ត៌មានរបស់ម្ចាស់ភាគហ៊ុននៅពេលដែលគាត់ធ្វើការសម្រេចចិត្តដោយខ្លួនឯង ថាត្រូវត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងធ្វើការថតចម្លងឯកសារទាំងនេះពីក្រុមហ៊ុនដោយមិនគិតថ្លៃ។ លើសពីនេះទៅទៀត មាត្រា២២៧ ក៏បញ្ជាក់ពីសិទ្ធិទទួលបានរបាយការណ៍ហិរញ្ញវត្ថុ និងឯកសារគាំទ្រនានាយ៉ាងតិច ២១ថ្ងៃ មុនប្រជុំមហាសន្និបាតប្រចាំឆ្នាំ (*សិទ្ធិទទួលបានព័ត៌មាន*)។ មាត្រា២៨៧

---

* មេធាវី **គឹម សាន** បានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់សេដ្ឋកិច្ចអន្តរជាតិ ពីសកលវិទ្យាល័យ Victoria University of Wellington) VUW) ប្រទេសណូវែលហ្សេឡង់។ បច្ចុប្បន្នលោកជាបេក្ខជន មជ្ឈត្តករពាណិជ្ជកម្ម នៃមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ម.ជ.) និងជាមន្ត្រីផ្តល់យោបល់ផ្នែកច្បាប់លើកិច្ចការរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោកធ្លាប់ជាអ្នកផ្តល់យោបល់ច្បាប់ផ្នែកបទបញ្ញត្តិពាណិជ្ជកម្មរបស់ក្រុមហ៊ុន Development Alternatives Inc. អ្នកផ្តល់យោបល់ច្បាប់ពាណិជ្ជកម្មក្នុងក្រុមមេធាវី Camlegal Asia)។

[1] See Julian Velasco, The Fundamental Rights of the Shareholder (2006), p 411.

[2] មាត្រានេះបានកំណត់ពីអំណាចក្នុងការដកហូតអភិបាលដោយសម្លេងរបស់ម្ចាស់ភាគហ៊ុនភាគច្រើន។ ការដកហូតអំណាចរបស់អភិបាលមានទំនាក់ទំនងដោយផ្ទាល់ជាមួយសិទ្ធិគ្រប់គ្រង ដោយហេតុថាអ្នកគ្រប់គ្រងមានសិទ្ធិតែងតាំង និងដកហូតអ្នកក្រោមបង្គាប់របស់ខ្លួន។

[3] សិទ្ធិនៃការចែកភាគលាភ របស់ម្ចាស់ភាគហ៊ុន តាមមាត្រា ១៥៧ ជាលទ្ធផលនៃការប្រកាសជាមុនរបស់អភិបាល។ មាត្រា ១៥៧ ចែងថា "ក្នុងករណីដែលមានការរឹតត្បិត នៅក្នុងលក្ខន្តិកៈ អភិបាលអាចប្រកាសចេញនូវភាគលាភសល់ ឬ ប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន។"

ចែងពីសិទ្ធិធ្វើបណ្ដឹងរបស់ម្ចាស់ភាគហ៊ុននៅពេលដែលការទាមទាររបស់ខ្លួនមិនត្រូវបានគេដោះស្រាយឲ្យ (*សិទ្ធិធ្វើបណ្ដឹង*)។[4]

ក្នុងតួសេចក្ដី នៃអត្ថបទនេះ អ្នកនិពន្ធនឹងលើកយកសិទ្ធិនីមួយៗមកពិភាក្សា ក្នុងបរិបទដោយឡែកៗ និងទំនាក់ទំនងរវាងសិទ្ធិមូលដ្ឋានដូចគ្នា ដើម្បីឆ្លុះបញ្ចាំងពីការយល់ដឹងសិទ្ធិនីមួយៗ។ លើសពីនោះទៅទៀត អ្នកនិពន្ធនឹងបង្ហាញថា ទោះបីជាមានការយល់ឃើញដោយឡែកៗអំពីប្រសិទ្ធិភាពនៃសិទ្ធិទាំងអស់នេះ សិទ្ធិទាំងអស់នេះជាមូលដ្ឋានចាំបាច់ ដើម្បីធានាពីតុល្យភាពអំណាច ស្របច្បាប់របស់ម្ចាស់ភាគហ៊ុន នៅក្នុងក្រុមហ៊ុន។

## ២.សិទ្ធិមូលដ្ឋានទាំងបួន

### ២.១ សិទ្ធិគ្រប់គ្រង

សិទ្ធិគ្រប់គ្រងក្រុមហ៊ុនជាញឹកញាប់ត្រូវបកស្រាយដោយ ភ្ជាប់ជាមួយសិទ្ធិកម្មសិទ្ធិ ដើម្បីសម្គាល់ដែនកំណត់នៃសិទ្ធិគ្រប់គ្រង និងប្រៀបធៀបទៅនឹងការគ្រប់គ្រងអចលនទ្រព្យ និងកម្មសិទ្ធិលើអចលនទ្រព្យ។ ជាតួយ៉ាង ម្ចាស់ដីដែលជួលដីឲ្យគេ(ភតិបតី) គឺបានបង្វែរសិទ្ធិគ្រប់គ្រងនោះឲ្យអ្នកជួលដី (ភតិកៈ) នៅក្នុងរយៈពេលជួលនោះ ប៉ុន្តែសិទ្ធិជាកម្មសិទ្ធិត្រូវតែជារបស់គាត់ដដែល។ នៅពេលដែលភតិបតីទទួលផលសេដ្ឋកិច្ចតាមរយៈអចលនទ្រព្យរបស់ខ្លួន (ថ្លៃជួលប្រចាំខែ) គាត់ក៏មានសិទ្ធិឲ្យភតិកៈគ្រប់គ្រងដីរបស់គាត់តាមសំណើរបស់គាត់ នឹងអាចដកហូតវិញនៅពេលដែលភតិកៈបំពានលើបញ្ញត្តិស្ដីពីការគ្រប់គ្រងដែលបានព្រមព្រៀង ឬផ្ទុយពីបញ្ញត្តិច្បាប់។ សិទ្ធិគ្រប់គ្រងជាសិទ្ធិសំខាន់បំផុតមួយ ចំណុះឲ្យសិទ្ធិកម្មសិទ្ធិ។ កម្មសិទ្ធិករនៃអចលនវត្ថុមួយ មានសិទ្ធិគ្រប់គ្រង លើអចលនវត្ថុនោះ។[5]

ទាក់ទងនឹងបញ្ហាក្រុមហ៊ុនវិញ ម្ចាស់ភាគហ៊ុន មានសិទ្ធិកម្មសិទ្ធិលើក្រុមហ៊ុន តាមចំណែកភាគហ៊ុនដែលខ្លួនមាន មិនថាម្ចាស់ភាគហ៊ុននោះធំ ឬតូចប៉ុណ្ណាទេ។ ម្ចាស់ភាគហ៊ុនមានសិទ្ធិគ្រប់គ្រងក្រុមហ៊ុន តាមរយៈការជ្រើសរើសអភិបាលឲ្យគ្រប់គ្រងធុរកិច្ចឲ្យខ្លួន និងការដកហូតអភិបាលចេញពីមុខតំណែង[6]។ អភិបាលត្រូវគេកំណត់ថាមានជំនាញ និងតួនាទី ក្នុង

---

[4] ទោះបីជាច្បាប់កម្ពុជាតម្រូវឲ្យគោរពល័ក្ខខណ្ឌមួយចំនួន មាត្រា ២៨៧ ដើម្បីធានានូវសិទ្ធិក្នុងការធ្វើបណ្ដឹងរបស់ម្ចាស់ភាគហ៊ុន មាត្រា ២៨៧ កថាខណ្ឌ១ ចែងថា "ម្ចាស់ហ៊ុនអាចប្ដឹង ឬធ្វើអន្តរាគមន៍ក្នុងនាម និងសិទ្ធិរបស់ក្រុមហ៊ុន"

[5] មាត្រា ៨៨ នៃច្បាប់ភូមិបាលកម្ពុជា ឆ្នាំ២០០១ ចែងពី "សិទ្ធិរបស់កម្មសិទ្ធិករ ក្នុងការកែប្រែដោយសេរី នូវប្រភេទ និងរចនាសម្ព័ន្ធដើម នៃទ្រព្យរបស់ខ្លួនស្របតាមការប្រើប្រាស់ដែលខ្លួនចង់ធ្វើតាមការកំណត់របស់ច្បាប់។" ឃ្លានេះបញ្ជាក់ពីសញ្ញាណនៃការគ្រប់គ្រង ដោយហេតុថាមានតែអ្នកគ្រប់គ្រងទេ ដែលអាចធ្វើសកម្មភាពតាមស្មារតីរបស់មាត្រានេះបាន។

[6] មាត្រា ១២៤ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម

ការគ្រប់គ្រង។ ទោះបីជាស្ថិតក្នុងការអនុវត្តជាក់ស្តែង ការគ្រប់គ្រង ដោយមិនផ្ទាល់នោះអាចមិនមានប្រសិទ្ធិភាពពេញលេញក៏ដោយ ប៉ុន្តែការណ៍នោះទាក់ទងនឹងរបៀបដែលម្ចាស់ភាគហ៊ុនត្រូវប្រើប្រាស់សិទ្ធិរបស់ខ្លួនទៅវិញទេ។[7] ម្ចាស់ភាគហ៊ុនត្រូវតែយល់ដឹងពីជំនាញធុរកិច្ច និងត្រៀមលក្ខណៈគ្រប់ពេលដើម្បីធានាសិទ្ធិគ្រប់គ្រងរបស់ខ្លួនឲ្យមានប្រសិទ្ធិភាព បូករួមទាំងជំនាញក្នុងការគ្រប់គ្រងការងាររបស់អភិបាលផង។ ម្ចាស់ភាគហ៊ុនតូចៗ ត្រូវចេះអនុវត្តសិទ្ធិគ្រប់គ្រងរបស់ខ្លួន និងប្រើប្រាស់ធនធានព័ត៌មានដើម្បីបំពេញឲ្យសិទ្ធិគ្រប់គ្រងដែលខ្លួនមាន។[8] ម្ចាស់ភាគហ៊ុនត្រូវតែទទួលផលវិបាកដែលកើតឡើងពីការខ្វះខាតរបស់ខ្លួន ក្នុងការអនុវត្តសិទ្ធិគ្រប់គ្រង។ ម្ចាស់ភាគហ៊ុនមាន "ជម្រើស" ដើម្បីអនុវត្តសិទ្ធិនេះដើម្បីធានាការពារផលប្រយោជន៍របស់ខ្លួន ប៉ុន្តែច្បាប់មិនអាច "បដិសេធ" ការអនុវត្តសិទ្ធិបានទេ។

## ២.២ សិទ្ធិសេដ្ឋកិច្ច

ភាគហ៊ុនត្រូវបានគេចាត់ទុកដូចជាទ្រព្យបុគ្គលដូច្នោះដែរ ដែលគេអាចទាញយកប្រយោជន៍ (ទទួលភាគលាភ) និងប្រែក្លាយវាឲ្យទៅជាប្រយោជន៍ជាប្រាក់កាស។ ដូច្នេះសិទ្ធិសេដ្ឋកិច្ច រួមមានសិទ្ធិទទួលបានភាគលាភ និងសិទ្ធិលក់ភាគហ៊ុន។ សិទ្ធិទទួលបានភាគលាភជាសិទ្ធិមួយសំខាន់ដើម្បីធានាពីផលដែលម្ចាស់ភាគហ៊ុនត្រូវទទួលនៅក្នុងរយៈពេលមួយ និងធ្វើឡើងដោយទៀងទាត់។ ទោះបីជាយ៉ាងណាក៏ដោយក្រុមហ៊ុនភាគច្រើន ជ្រើសរើសចែកភាគលាភក្នុងកម្រិតមួយនៃប្រាក់ចំណេញសរុប ទៅម្ចាស់ភាគហ៊ុន។[9] សិទ្ធិលក់ភាគហ៊ុន មានទំនាក់ទំនងជាមួយនឹងសិទ្ធិកម្មសិទ្ធិ នៅពេលម្ចាស់ភាគហ៊ុនជាម្ចាស់ហ៊ុនស្របច្បាប់នោះ លក់ហ៊ុនរបស់គាត់ ទៅតាមទម្រង់ដែលកំណត់ដោយវិធានរបស់ក្រុមហ៊ុន និងតាមការចាត់ចែងរបស់អភិបាល។ សិទ្ធិសេដ្ឋកិច្ចមានទំនាក់ទំនងជាមួយសិទ្ធិគ្រប់គ្រងនៅពេលដែលម្ចាស់ភាគហ៊ុនបានតែងតាំងអភិបាល ដើម្បីឲ្យគ្រប់គ្រងធុរកិច្ចជំនួសខ្លួន ហើយការគ្រប់គ្រងធុរកិច្ចនោះបានជាប្រយោជន៍សេដ្ឋកិច្ចដល់ម្ចាស់ភាគហ៊ុន។ តាមទស្សនៈបែបប្រពៃណី គឺក្រុមហ៊ុនមាន

[7] សាស្ត្រាចារ្យ Adolf A. Berle, Jr., និងGardiner C. Means បានលើកហេតុផលនៅក្នុងអំណះអំណាងរបស់ខ្លួនថា ម្ចាស់ភាគហ៊ុនគ្មានអំណាចគ្រប់គ្រងទេ ពេលតទល់ជាមួយក្រុមអ្នកគ្រប់គ្រង (Management Team)។ Adolf A. Berle, Jr., និង Gardiner C. Means, សារជីវកម្មទំនើប និងទ្រព្យឯកជន "THE MODERN CORPORATION AND PRIVATE PROPERTY" (1932).

[8] ការយល់ឃើញនេះ ជាការឆ្លើយតប នឹងអត្ថបទរបស់ Bernard S.Black, Shareholder Passivity Reexamined (ពិនិត្យមើលឡើងវិញពីភាពអសកម្មរបស់ម្ចាស់ភាគហ៊ុន) , 89 Mich. L. REV. 520, 526-29 (1990)

[9] ប្រទេសកម្ពុជា មិនមានការបើកទូលាយស្ថិតិស្តីពីការបែងចែកភាគហ៊ុន។ ស្ថិតិនៅសហរដ្ឋអាមេរិកតាមអត្ថបទរបស់ Floyd Norris, Cash Flow in 04 Found Its Way Into Dividends, N.Y. TIMES, JAN.4, 2005, At C1.

គោលដៅរកប្រាក់ចំណេញឲ្យម្ចាស់ភាគហ៊ុន ចំណែកគោលដៅរបស់អភិបាល គឺការគ្រប់គ្រងដើម្បីបង្កើនឲ្យបានជាអតិបរមានូវទ្រព្យរបស់ម្ចាស់ភាគហ៊ុន។[10]

ជាក់ស្តែង ម្ចាស់ភាគហ៊ុនអាចរួមគ្នាក្នុងចុះកិច្ចព្រមព្រៀងដាក់ដែនកំណត់ក្នុងការលក់ហ៊ុន ដើម្បីហេតុផល នៃការវិនិយោគរយៈពេលវែង។ ប៉ុន្តែហេតុផលនេះ មិនត្រូវហាមឃាត់ការលក់ហ៊ុនឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ការលក់ហ៊ុនត្រូវធ្វើតាមបែបបទច្បាស់លាស់ដែលទាមទារឲ្យមានការទទួលស្គាល់ពីម្ចាស់ភាគហ៊ុនដទៃទៀតជាមុន។ ការលក់ភាគហ៊ុន មិនត្រូវធ្វើឲ្យប៉ះពាល់ដល់ប្រតិបត្តិការធុរកិច្ចទេ ដោយហេតុថាធុរកិច្ចគឺចាត់ចែងដោយអភិបាលដោយផ្ទាល់ និងមិនចាត់ចែងដោយផ្ទាល់ពីម្ចាស់ភាគហ៊ុនឡើយ។[11] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មកម្ពុជាហាក់ដូចជាមិនបានហាមឃាត់ម្ចាស់ភាគហ៊ុនដែលមានភាគហ៊ុនសំខាន់ (controlling shareholder) មិនឲ្យលក់ហ៊ុនរបស់ខ្លួនទៅអ្នកដែលអាចចោទជាគ្រោះថ្នាក់ដល់ម្ចាស់ភាគហ៊ុនតិចដទៃទៀតទេ។ ច្បាប់នេះមិនបានតម្រូវ កាតព្វកិច្ចផ្តល់ការទុកចិត្តចំពោះម្ចាស់ភាគហ៊ុន (fiduciary duties on a shareholder) ឡើយ។[12]

## ២.៣ សិទ្ធិទទួលបានព័ត៌មាន

ព័ត៌មានជាវត្ថុសំខាន់ដើម្បីជួយឲ្យម្ចាស់ភាគហ៊ុន ឬបេក្ខជនដែលនឹងក្លាយជាម្ចាស់ភាគហ៊ុន ឬអ្នកវិនិយោគគិតគូរ និងសម្រេចពីការចូលរួមរបស់ខ្លួននៅក្នុងក្រុមហ៊ុន។ ជាពិសេសសម្រាប់ម្ចាស់ភាគហ៊ុនដែលមានស្រាប់ គាត់អាចសម្រេចថាតើត្រូវបន្ថែម ឬបន្ថយ ឬដកយកមកវិញដើមទុនវិនិយោគរបស់ខ្លួន ប្រសិនបើមិនទុកចិត្តដោយប្រការណាមួយ។ ព័ត៌មាននោះអាចជួយដល់ការសម្រេចចិត្ត ថាទទួលអ្នកវិនិយោគឲ្យចូលជាម្ចាស់ភាគហ៊ុនថ្មីឬទេ។[13] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ចែងពីសិទ្ធិទទួលបានព័ត៌មាន របស់ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនមួយ។ ដោយហេតុថាម្ចាស់ភាគហ៊ុនគឺជា ម្ចាស់ទាំងអស់គ្នារបស់ក្រុមហ៊ុន ហើយអំណាចចាត់ចែងកិច្ចការរបស់ម្ចាស់ភាគហ៊ុន ត្រូវបានអនុវត្តតាមរយៈអភិបាល ច្បាប់នេះបានពន្យល់ថា ម្ចាស់ភាគហ៊ុនមានសិទ្ធិទទួលបានរបាយការណ៍ហិរញ្ញវត្ថុនានា ដែលត្រូវផ្តល់ជូន

[10] See Dodge v. Ford Motor Co., 170 N.W. 668, 684 (Mich. 1919); E. Merrick Dodd, Jr., For Whom Are Corporate Mangers Trustees?, 45 HARV.L.REV. 1145, 1145 (1932); Milton Friedman, A Friedman Doctrine- The Social Responsibility of Business Is to Increase Its Profits, N.Y. TIMES, Sep. 13, 1970, at SM17.

[11] See Julian Velasco, the fundamental Rights of the Shareholder (2006), p 415.

[12] ដោយហេតុថាម្ចាស់ភាគហ៊ុនសំខាន់គ្រប់គ្រងទ្រព្យរបស់ ក្រុមហ៊ុន និងទ្រព្យរបស់ម្ចាស់ភាគហ៊ុនតិច ម្ចាស់ភាគហ៊ុនសំខាន់មានកាតព្វកិច្ចផ្តល់ការទុកចិត្តចំពោះម្ចាស់ភាគហ៊ុនភាគតិច។ See Zipora Cohen, Fiduciary duties of Controlling Shareholders: A comparative view (1991), p 380.

[13] See Julian Velasco, the fundamental Rights of the Shareholder (2006), p 426.

ដោយអភិបាលនៅពេលប្រជុំសន្និបាតប្រចាំឆ្នាំ នៃម្ចាស់ភាគហ៊ុន។ ព័ត៌មានដែលត្រូវទទួលបាននេះ ជាការចាំបាច់ក្នុងការសម្រេចចិត្តធំៗនៅពេលមានប្រជុំទៀងទាត់ ហើយតាមលក្ខណៈរបស់មាត្រា ២២៤ រួមមានរបាយការណ៍ហិរញ្ញវត្ថុប្រៀបធៀបពីគ្រាមុន របាយការណ៍សវនករព័ត៌មានទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឯកសារប្រតិបត្តិការក្រុមហ៊ុនមួយចំនួនលក្ខន្តិកៈក្រុមហ៊ុន កិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុនដែលបានសម្រេចជាឯកឆន្ទ។

ជាទូទៅ សិទ្ធិទាំងនេះមិនអាចអនុវត្តបានពេញលេញដោយគ្មានការទទួលខុសត្រូវរបស់អភិបាលដែលត្រូវបានតែងតាំងដំបូងបំផុតដោយម្ចាស់ភាគហ៊ុន ដើម្បីចាត់ចែងក្រុមហ៊ុនជំនួសមុខឲ្យម្ចាស់ភាគហ៊ុនឡើយ។ ទោះបីជាឯកសារដែលត្រូវការឲ្យមានខាងលើ ត្រូវតែបញ្ជូនទៅម្ចាស់ភាគហ៊ុនណាម្នាក់ ការបញ្ជូនឯកសារ អាចត្រូវបានគេចោទសួរពីភាពស្មោះត្រង់នៅគ្រប់ពេល។ ស្ថានភាពនេះតម្រូវឲ្យម្ចាស់ភាគហ៊ុនទាំងឡាយធ្វើការរួមគ្នា ដើម្បីគិតទុកជាមុន ឬដោយមានជំនួយពីមេធាវីពាណិជ្ជកម្មរបស់ខ្លួនដើម្បីកំណត់ពីឯកសារសំខាន់អ្វីខ្លះដែលអភិបាលត្រូវការផ្តល់ជូន ដើម្បីការពារសិទ្ធិទទួលបានព័ត៌មាន ដូចមានបញ្ញត្តិនៅក្នុងច្បាប់។

ទោះបីជា សិទ្ធិក្នុងការពិនិត្យមើលឯកសារ អាចត្រូវសម្រេចបាននៅគ្រប់ម៉ោងធ្វើការការណ៍នេះមិនបានធានាឲ្យមានសិទ្ធិមូលដ្ឋាន ដើម្បីសម្រេចបានការទទួលឯកសារពេញលេញនិងដោយស្មោះត្រង់ឡើយ។ ជាពិសេស នៅកាលៈទេសៈខ្លះ វិធានតឹងតែងមួយចំនួនដែលអនុម័តដោយអភិបាល ក៏អាចជាឧបសគ្គដល់ការបើកចំហរឯកសារទាំងនោះដែរ។[14]

## ២.៤ សិទ្ធិធ្វើបណ្តឹង

សិទ្ធិនៃការស្វែងរកការសម្រេចរបស់តុលាការ តាមរយៈបណ្តឹងជំនួសមុខ មានបញ្ជាក់ច្បាស់នៅក្នុងមាត្រា ២៨៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ទោះបីជាមានលក្ខខណ្ឌរឹតត្បិតមួយចំនួន[15] មុននឹងម្ចាស់ភាគហ៊ុនទទួលបានសិទ្ធិធ្វើបណ្តឹងជួសមុខឲ្យក្រុមហ៊ុន សិទ្ធិនេះជាសិទ្ធិចាំបាច់ នៅក្នុងការកំណត់ពីការទទួលខុសត្រូវរបស់ម្ចាស់ភាគហ៊ុនចំពោះដំណើរការរបស់ក្រុមហ៊ុន។ លក្ខខណ្ឌរឹតត្បិតទាំងនេះមិនបានបន្ថយសិទ្ធិ ឬសមត្ថភាពប្តឹងរបស់ម្ចាស់ភាគហ៊ុនទេ។ ផ្ទុយទៅវិញ ម្ចាស់ភាគហ៊ុនទទួលបាននូវការមិនរើសអើង និងតបស្នងតាមផ្លូវច្បាប់

[14] មាត្រា ២២៥ ចែងថា "យោងតាមសំណើររបស់ខ្លួន ម្ចាស់ហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងម៉ោងធ្វើការរបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបានដោយឥតគិតថ្លៃ។"

[15] ការរឹតត្បិតមួយចំនួនជាល័ក្ខខ័ណ្ឌដែលសម្គាល់ថាម្ចាស់ភាគហ៊ុនបានប្រើប្រាស់អស់នូវការព្យាយាមដោះស្រាយផ្ទៃក្នុងជាមុន តាមមាត្រា ២៨៧ រួមមាន ១.ភាពជាម្ចាស់ហ៊ុន ឬអ្នកស្នងមរតករបស់ម្ចាស់ហ៊ុន ២.មិនបានធ្វើការគាំទ្រជាមុន តាមរយៈការបោះឆ្នោត ការឲ្យសច្ចានុម័ត ៣. កាតព្វកិច្ចជូនដំណឹងទៅក្រុមប្រឹក្សាភិបាល មុនពេលបញ្ជូនបណ្តឹងទៅតុលាការ

ចំពោះចំណាត់ការរបស់ខ្លួនដូចជា ១. បណ្តឹងជំនួសមុខមិនអាចដកមកដោះស្រាយផ្ទៃក្នុងក្រុមហ៊ុនវិញទេ បើគ្មានការព្រមព្រៀងពីតុលាការ (អនុភាពនៃបណ្តឹង)[16] ២. ប្រាក់សំណងពីការឈ្នះ នៃបណ្តឹង ត្រូវបានជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន (ការទទួលស្គាល់ចំណាត់ការបណ្តឹង)[17] និង ៣. សិទ្ធិពិសេសក្នុងការទាមទារឲ្យតុលាការសម្រេចផ្តល់សំណងឲ្យខ្លួន(ម្ចាស់ភាគហ៊ុនដែលបានប្តឹង) សមស្រប។[18]

តាមបទដ្ឋានបច្ចេកទេស ក្រុមប្រឹក្សាភិបាលជាអ្នកសម្រេចថាត្រូវធ្វើឬមិនបណ្តឹងក្នុងនាមក្រុមហ៊ុន។ ប៉ុន្តែប្រសិនបើក្រុមប្រឹក្សាភិបាលមិនបានដោះស្រាយ និងធ្វើការសម្រេចចិត្តលើទំនាស់ដែលបានតវ៉ាជាលាយល័ក្ខណ៍អក្សរទេ ម្ចាស់ភាគហ៊ុននឹងប្រើប្រាស់សិទ្ធិនេះបាន។[19] កិច្ចការនាំបណ្តឹងទៅតុលាការដែលម្ចាស់ភាគហ៊ុនធ្វើ គឺធ្វើឡើងដើម្បីពង្រឹងសិទ្ធិស្របច្បាប់របស់ខ្លួន[20] ក៏ដូចជាសិទ្ធិរបស់ក្រុមហ៊ុនទាំងមូល[21]។ ម្ចាស់ភាគហ៊ុនជានិច្ចជាកាលធ្វើបណ្តឹងប្រឆាំងនឹងសកម្មភាព គ្រប់គ្រងធ្វេសប្រហែស ការគ្រប់គ្រងមិនមានប្រសិទ្ធិភាព ឬការគ្រប់គ្រងបែបពុករលួយ របស់ក្រុមប្រឹក្សាភិបាល ឬរបស់អភិបាលដែលនឹងក្លាយជាតតិយជន ប្រសិនបើទទួលរងបណ្តឹងបែបនេះ។[22] រាល់ជម្លោះរវាងម្ចាស់ភាគហ៊ុន និងអភិបាលក៏អាចដោះស្រាយក្រៅប្រព័ន្ធតុលាការដែរ ប៉ុន្តែត្រូវមានបញ្ញត្តិជាមុននៅក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។ ការដោះស្រាយក្រៅប្រព័ន្ធតុលាការដែលច្បាប់កម្ពុជាផ្តល់ជាជម្រើសនោះ គឺមជ្ឈមណ្ឌលមជ្ឈត្តកម្ម។[23] ទោះបីជាយ៉ាងណាក៏ដោយ បណ្តឹងចំពោះមុខក៏អាចធ្វើតទល់នឹងតតិយជនដទៃទៀត ក្រៅពីអភិបាលរបស់ក្រុមហ៊ុនដែរ។

[16] មាត្រា ២៨៧ កថាខណ្ឌ ៦

[17] ការទទួលបានសិទ្ធិសេដ្ឋកិច្ចរួមសម្រាប់ក្រុមហ៊ុនមកវិញ (Restoration of Economic Rights). មាត្រា ២៨៨

[18] មាត្រា ២៨៨

[19] មាត្រា ២៨៧ កថាខណ្ឌ គ

[20] See Julian Velasco, the fundamental Rights of the Shareholder (2006), p 423.

[21] See International Journal of Law ISSN: 2455-2194, RJIF 5.12 www.lawjournals.org Volume 3; Issue 3; May 2017; Page No. 102

[22] See International Journal of Law ISSN: 2455-2194, RJIF 5.12 www.lawjournals.org Volume 3; Issue 3; May 2017; Page No. 102

[23] មាត្រា ២៨៩ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម.។ "មជ្ឈមណ្ឌលមជ្ឈត្តកម្ម" ក្នុងមាត្រានេះ ទំនងសំដៅដល់" "មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម" ដែលមជ្ឈមណ្ឌលនេះទទួលដោះស្រាយតែវិវាទពាណិជ្ជកម្មប៉ុណ្ណោះ (មាត្រា ១ នៃច្បាប់ស្តីពីមជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម)។ ដូច្នេះចំណុចវិវាទរវាងម្ចាស់ភាគហ៊ុន និងអភិបាល ត្រូវគោរពលក្ខខណ្ឌដែលសម្គាល់ថាជា វិវាទផ្នែកពាណិជ្ជកម្ម ជាមុនសិន។ ប្រសិនបើមជ្ឈមណ្ឌលនេះយល់ថា ជាវិវាទការងារ នោះទំនាស់នេះអាចមិនត្រូវទទួលដោះស្រាយឡើយ។ ដើម្បីស្វែងយល់បន្ថែម ថាអ្វីទៅហៅថាចំណុចវិវាទផ្នែកពាណិជ្ជកម្ម សូមមើលអត្ថបទផ្សាយ "ចំណុចវិវាទដែលអាចសម្រេចសេចក្តីបានដោយ

## ៣. សេចក្ដីសន្និដ្ឋាន

សិទ្ធិទាំង៤ (*សិទ្ធិគ្រប់គ្រង សិទ្ធិខាងសេដ្ឋកិច្ច សិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិធ្វើបណ្ដឹង)* ជាសិទ្ធិចាំបាច់នៅក្នុងការធានាពីតុល្យភាពអំណាចនៅក្នុងក្រុមហ៊ុន នឹងត្រូវធានាឲ្យបាននៅក្នុងយន្តការទ្រឹស្ដី (លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងឯកសារបំពេញកិច្ចក្រុមហ៊ុននានា) និងការអនុវត្ត។ *សិទ្ធិធ្វើបណ្ដឹង* មានសារៈសំខាន់ និងមានតម្លៃ ក្នុងការពង្រឹងការអនុវត្តសិទ្ធិដទៃទៀតរបស់ម្ចាស់ភាគហ៊ុន។[24] សិទ្ធិក្នុងការជ្រើសរើស និងដកហូតអភិបាល ជាសិទ្ធិសំខាន់មួយទៀត ស្ថិតនៅក្រោមខ្សែបណ្ដាយ នៃ*សិទ្ធិគ្រប់គ្រង*។ ការជ្រើសរើសអភិបាល ជាវិធី ដែលម្ចាស់ភាគហ៊ុនអនុវត្តសិទ្ធិគ្រប់គ្រងរបស់ខ្លួន។ សិទ្ធិនេះត្រូវតែបានគិតគូរយ៉ាងម៉ត់ចត់ និងត្រូវទទួលស្គាល់ឲ្យមានប្រសិទ្ធិភាព ដោយសារវាផ្សារភ្ជាប់នឹងសិទ្ធិកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុនព្រមទាំងជាបទដ្ឋានមួយរបស់សិទ្ធិកម្មសិទ្ធិផងដែរ[25]។ *សិទ្ធិទទួលបានព័ត៌មាន* មានភាពចាំបាច់ទៅទៀត។ បើគ្មានព័ត៌មានពីប្រតិបត្តិការរបស់ក្រុមហ៊ុនទេ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិគ្រប់គ្រងក្រុមហ៊ុននឹងត្រូវទទួលផលប៉ះពាល់ជាក់ជាពុំខាន និងមិនសូវមានតម្លៃដូចពេលទទួលបានព័ត៌មានគ្រប់គ្រាន់ឡើយ[26]។ សិទ្ធិទទួលបានភាគលាភ និងសិទ្ធិលក់ភាគហ៊ុន ចំណុះឲ្យ*សិទ្ធិសេដ្ឋកិច្ច* ដែលសិទ្ធិទាំងនេះមិនអាចទទួលបានពេញលេញទេ ប្រសិនបើសិទ្ធិគ្រប់គ្រងតាមរយៈការតែងតាំងក្រុមប្រឹក្សាអភិបាល មិនបានតំណាងឲ្យឆន្ទៈ និងបំណងរបស់ម្ចាស់ភាគហ៊ុន។ សិទ្ធិក្នុងការផ្ទេរភាគហ៊ុន ជាចំណែកមួយរបស់*សិទ្ធិសេដ្ឋកិច្ច* និង ជាបទដ្ឋានមួយ របស់សិទ្ធិកម្មសិទ្ធិ។ ម្ចាស់ភាគហ៊ុនអាចប្រើប្រាស់សិទ្ធិផ្ទេរភាគហ៊ុន ឬសិទ្ធិលក់ហ៊ុន ក៏ដូចជាសិទ្ធិតែងតាំងអភិបាលដើម្បីការពារខ្លួនឯង (សិទ្ធិការពារខ្លួន)។

---

វេទិកាមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា" ដោយ មេធាវី គឹម សាន ព្រឹត្តិប័ត្រមេធាវី ត្រីមាសទី៣ លេខ ១៤ កក្កដា-កញ្ញា ២០១៧។

[24] Julian Velasco, សិទ្ធិជាមូលដ្ឋាននៃម្ចាស់ភាគហ៊ុន "the Fundamental Rights of the Shareholder" (2006), p 427.

[25] Julian Velasco, កម្មសិទ្ធិនិងភាពជាម្ចាស់ភាគទុនិក "Shareholder Ownership and Primacy" (2010), p 951

[26] Julian Velasco, សិទ្ធិជាមូលដ្ឋាននៃម្ចាស់ភាគហ៊ុន (2006), p 426.